ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

# របាយការណ៍កិច្ចប្រជុំ
# ក្រុមប្រឹក្សាបច្ចេកទេសអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

**១. ថ្ងៃ ខែ ឆ្នាំ ៖** ថ្ងៃចន្ទ ៩កើត ខែជេស្ឋ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០ ត្រូវនឹងថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២៦

**២. ទីកន្លែង ៖** អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងតាមប្រព័ន្ធនិម្មិត(Zoom)។

**៣. ប្រធាន និងសមាសភាពចូលរួម ៖**

៣-១- ប្រធានអង្គប្រជុំ **ឯកឧត្តមបណ្ឌិត ឈឹម យិនដារ៉េត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

៣-២-សមាសភាពចូលរួមមាន សមាជិក សមាជិកាថ្នាក់បច្ចេកទេសអន្តរក្រសួង ស្ថាប័ន រាជធានី ខេត្ត អង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធ ដែលមានសមាជិកចូលរួមនៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ចំនួន៤៤រូប និងតាមប្រព័ន្ធនិម្មិត(Zoom) ចំនួន៣៨គណនី។

**៤. របៀបវារៈ៖**

៤.១ មតិស្វាគមន៍ និងគោលបំណងរបស់ **ឯកឧត្តមបណ្ឌិត ឈឹម យិនដារ៉េត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងជាប្រធានក្រុមប្រឹក្សាបច្ចេកទេស។

៤.២ ពិនិត្យនូវវឌ្ឍនភាពនៃការឆ្លើយតបនឹងមេរោគអេដស៍

៤.៣ ពិនិត្យ និងពិភាក្សា ទម្រង់របាយការណ៍ស្តីពីការជំរុញការអនុវត្តគោលនយោបាយជាតិបញ្ចប់អេដស៍ និងចីរភាពកម្មវិធីអេដស៍សម្រាប់ឆ្នាំ២០២៣-២០២៨

៤.៤ មតិបូកសរុប និងបិទកម្មវិធីដោយ **ឯកឧត្តមបណ្ឌិត ឈឹម យិនដារ៉េត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

**៥. សកម្មភាព និងលទ្ធផល៖**

ជាបឋម **ឯកឧត្តមបណ្ឌិត ឈឹម យិនដារ៉េត** អគ្គលេខាធិការនៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានថ្លែងនូវមតិស្វាគមន៍ដល់ក្រុមការងារនិងអង្គប្រជុំ បានថ្លែងនូវការកោតសរសើរក្រុមការងារក៏ដូចជាក្រសួង ស្ថាប័ន រាជធានី ខេត្ត ដែលបានប្រឹងប្រែងចូលរួមក្នុងការអនុវត្តការឆ្លើយតបនឹងមេរោគអេដស៍កន្លងមក។ ការសម្រេចបាននូវលទ្ធផលល្អប្រសើរកន្លងមកនេះ ដោយសារមានការយកចិត្តទុកដាក់គិតគូប្រកបដោយគតិបណ្ឌិតរបស់**សម្តេចធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី** នៃព្រះរាជាណាចក្រកម្ពុជា ដោយមានចូលរួមអនុវត្តពីគ្រប់ភាគីពាក់ព័ន្ធទាំងផ្នែកជាតិ អន្តរជាតិ និងសង្គមស៊ីវិល ក្រោមការដឹកនាំប្រកប

ដោយភាពឈ្លាសវៃ **ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង មូលី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ក្នុងការឈានទៅសម្រេចបានគោលនយោបាយជាតិទាំងបី៖

១- កាត់បន្ថយការចម្លងថ្មីតិចជាង ១នាក់ ឬប្រមាណជា ២០០នាក់ក្នុងមួយឆ្នាំ។

២- កាត់បន្ថយការស្លាប់ដោយសារមេរោគអេដស៍ឱ្យនៅក្រោម ២០០នាក់ក្នុងមួយឆ្នាំ។

៣- លុបបំបាត់ការមាក់ងាយ និងរើសអើង។

**ឯកឧត្តមបណ្ឌិត**ក៏បានជម្រាបជូនអង្គប្រជុំ ពីការរៀបចំនូវកិច្ចប្រជុំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ស្តីពីការជំរុញការអនុវត្តគោលនយោបាយជាតិបញ្ចប់អេដស៍ និងចីរភាពកម្មវិធីអេដស៍សម្រាប់ឆ្នាំ២០២៣-២០២៨ ដែលនឹងប្រព្រឹត្តនៅសណ្ឋាគារឯករាជ្យ ខេត្តព្រះសីហនុ នាថ្ងៃទី៣-៤ ខែកុម្ភៈ ឆ្នាំ២០២៦ ដែលនឹងកំណត់នូវសូចនាករសមិទ្ធកម្មសម្រាប់ក្រសួង ស្ថាប័ន រាជធានី ខេត្ត អនុលោមទៅនឹងសេចក្តីសម្រេចរបស់គណៈរដ្ឋមន្ត្រី។ **ឯកឧត្តមបណ្ឌិត** បានអនុញ្ញាតឱ្យលោកវេជ្ជបណ្ឌិត ទេព ណារុជ ប្រធាននាយកដ្ឋានផែនការ ត្រួតពិនិត្យ វាយតម្លៃ និងស្រាវជ្រាវ ធ្វើបទបង្ហាញពីទម្រង់របាយការណ៍ ស្តីពីអនុវត្តគោលនយោបាយជាតិបញ្ចប់អេដស៍ និងចីរភាពកម្មវិធីអេដស៍សម្រាប់ឆ្នាំ ២០២៣-២០២៨។

**លោកវេជ្ជបណ្ឌិត ទេព ណារុជ** ប្រធាននាយកដ្ឋានផែនការ ត្រួតពិនិត្យ វាយតម្លៃ និងស្រាវជ្រាវ បានបង្ហាញ និងបានពន្យល់ពីទម្រង់របាយការណ៍យ៉ាងលម្អិត ដោយលោកបញ្ជាក់ថា ទម្រង់របាយការណ៍នេះចែកពីរផ្នែកធំៗគឺៈ ផ្នែកទី១ ជាទម្រង់របាយការណ៍សង្ខេប និងផ្នែកទី២ ជាទម្រង់របាយការណ៍លម្អិត។ ទម្រង់របាយការណ៍នេះ មានសូចនាករប្រែប្រួលទៅតាមក្រសួង ស្ថាប័ន រាជធានី ខេត្ត ដែលកំពុងអនុវត្តគោលនយោបាយជាតិរបស់រាជរដ្ឋាភិបាល។ បន្ទាប់មក**លោកវេជ្ជបណ្ឌិត** បានជូនដល់សមាជិកអង្គប្រជុំក្នុងការពិភាក្សានិងឆ្លើយតបទៅនឹងសំនួរនានា លើទម្រង់របាយការណ៍នេះ។

បញ្ជាក់លើទម្រង់របាយការណ៍នេះ **ឯកឧត្តមបណ្ឌិត ស៊ឹម សូផៃ** អគ្គលេខាធិការរង អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងជាអនុប្រធានក្រុមប្រឹក្សាបច្ចេកទេសបានជម្រាបអង្គប្រជុំពីវឌ្ឍនភាពស្ថានភាពនៃការឆ្លើយតបនឹងមេរោគអេដស៍ថា ក្នុងឆ្នាំ២០២៤ កម្ពុជាមានអត្រាផ្ទុកមេរោគអេដស៍ចំនួន ០.៥ភាគរយ មានអ្នកផ្ទុកមេរោគអេដស៍ប្រមាណ ៧៦ ០០០នាក់ និងមានអ្នកឆ្លងថ្មីប្រមាណជា ១ ២០០នាក់ ដែលក្នុងនោះប្រមាណជា ៨៨ភាគរយ ជាក្រុមប្រជាជនគន្លឹះនិងអតិថិជនរួមនឹងដៃគូ និងភាគច្រើនជាយុវវ័យ។ ជាពិសេសប្រមាណ ៤០ភាគរយ ក្នុងចំណោមអ្នកឆ្លងថ្មី ជាក្រុមយុវវ័យចន្លោះអាយុពី១៥-២៤ឆ្នាំ។ ជាបន្ត **ឯកឧត្តមបណ្ឌិត** បានជម្រាបថា គោលបំណងនៃនវានុវត្តន៍ទម្រង់របាយការណ៍គឺឆ្លើយតបនឹង៖

- ការបង្កើនការយល់ដឹងលើការអនុវត្តគោលនយោបាយជាតិបញ្ចប់អេដស៍ និងចីរភាពកម្មវិធីអេដស៍សម្រាប់ឆ្នាំ២០២៣ ២០២៨។
- កំណត់បានសូចនាករសម្រាប់ក្រសួង ស្ថាប័ន រាជធានី ខេត្ត ស្របតាមភារកិច្ច ដូចដែលមានចែងក្នុងឧបសម្ព័ន្ធទី១នៃគោលនយោបាយជាតិបញ្ចប់អេដស៍ និងចីរភាពកម្មវិធីអេដស៍សម្រាប់ឆ្នាំ២០២៣-២០២៨។

- ជំរុញការអនុវត្តលិខិតលេខ២១៣ សជណ.កប ចុះថ្ងៃទី៨ ខែមករា ឆ្នាំ២០២៦ ស្តីពីករណីវិធានការជំរុញប្រសិទ្ធភាពនៃការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- ធ្វើឱ្យកាន់តែប្រសើរឡើងនូវយន្តការនៃការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍រវាងថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

ជាចុងក្រោយ **ឯកឧត្តមបណ្ឌិត** បានផ្តល់នូវមតិ និងអនុសាសន៍ដល់កិច្ចប្រជុំដូចខាងក្រោម៖

- សូមបំពេញនូវទម្រង់របាយការណ៍ទាំងពីរ (របាយការណ៍វឌ្ឍនភាព និងរបាយការណ៍តាមដានការអនុវត្តគោលនយោបាយតាមក្រសួង ស្ថាប័ន រាជធានីខេត្ត) នឹងបញ្ជូនត្រឡប់មកវិញឱ្យបានមុនសប្តាហ៍ទី២ ខែមិថុនា ឆ្នាំ២០២៦)
- សូមទម្លាក់នូវសំណួរទាក់ទងនឹងកម្រងរបាយការណ៍ ទៅក្នុងក្រុមតេលេក្រាមក្រុមប្រឹក្សាបច្ចេកទេស ប្រសិនបើមានចម្ងល់។

កិច្ចប្រជុំបានដំណើរការទៅតាមរបៀបវារៈដែលបានគ្រោងទុក និងបញ្ចប់នៅវេលាម៉ោង ដប់មួយព្រឹកថ្ងៃខែឆ្នាំដដែល ប្រកបដោយលទ្ធផលផ្លែផ្កា។ ជាទីបញ្ចប់នៃកិច្ចប្រជុំ **ឯកឧត្តមបណ្ឌិត** បានជូនពរដល់សមាជិកអង្គប្រជុំ ឱ្យជួបប្រទះតែនឹងពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

ថ្ងៃសុក្រ ១៣កើត ខែជេស្ឋ ឆ្នាំមមី អដ្ឋស័ក ព.ស២៥៧០
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២៦

**បានឃើញ និងឯកភាព**
**អគ្គលេខាធិការ**

**បណ្ឌិត ឈឹម មិនជាវ៉េត**

**បានពិនិត្យត្រឹមត្រូវ**
**ប្រធាននាយកដ្ឋានទាក់ទង និងចលនាប្រភាពធនធាន**

**វេជ្ជ. ហួត សេរីវង្ស**

**អ្នកធ្វើរបាយការណ៍**

**ស៊ុំ ផល្លា**